| កិច្ចតែងការ | |
|---|---|
| **មុខវិជ្ជា** | សិក្សាសង្គម |
| **ប្រធានបទ** | គំនូរ និងសកម្មភាពកសាង |
| **ចំណងជើងមេរៀន** | លាយពណ៌ធ្វើជារូបសត្វមេអំបៅ(ដកស្រង់ពីរឿងតើនរណាជាអ្នកលាបពណ៌មេឃ?) |
| **កម្រិត** | ទាប ៣០ នាទី |
| **គោលបំណង** | គូរ និងផាត់ពណ៌ដើម្បីបង្កើតរូបភាពផ្សេងៗ និងបង្ហាញពីអ្វីដែលគេបានបង្កើត។ |
| **បំណិនសម្បទា** | គូរ និងផាត់ពណ៌គំនូរបានត្រឹមត្រូវ។ |
| **ចរិយាសម្បទា** | ស្រឡាញ់ចូលចិត្ត អំណត់ ព្យាយាម ឆ្នៃប្រឌិត និង ចេះទទួលស្គាល់ស្នាដៃរបស់ខ្លួន។ |
| **គ្រូបង្រៀន (សម្ភារឧបទេស)** | ទឹកពណ៌ក្រហម លឿង និងពណ៌ខៀវ ក្រដាសស ចាន ជក់។ |
| **កុមារ** | ទៅតាមស្ថានភាពជាក់ស្តែង |
| **រៀបចំ** | ទីកន្លែងសម្រាប់លាយពណ៌ ក្រដាស់ ចាន ជក់ ទឹក ...) |

| **សកម្មភាពគ្រូបង្រៀន** | **មាតិកា** | **សកម្មភាពសិស្ស** |
|---|---|---|
| 1. បង្ហាញក្មេងៗពីទឹកពណ៌និងសួរថាពណ៌ណាដែលជាពណ៌ដែលពួកគេចូលចិត្ត។<br>2. សរសេរពណ៌នៅលើក្តារខៀន | 1. បត់ក្រដាសពាក់កណ្តាលជាមួយខាងគែមខ្ចីទៅខាងគែមខ្ចីដូចគ្នា។ | 1. ស្តាប់គ្រូ និងឆ្លើយសំណួររបស់លោកគ្រូ អ្នកគ្រូ។<br>2. បត់ក្រដាស់របស់អ្នកជាពាក់កណ្តាល។ |

| | | |
|---|---|---|
| 3. ពន្យល់ថាពណ៌ក្រហម ពណ៌លឿង និងពណ៌ខៀវ គឺជាពណ៌ដើម។ គ្មានពណ៌ណាផ្សេងទៀតដែលអាចលាយចេញពណ៌ក្រហម លឿង និងពណ៌ខៀវនោះទេ តែពណ៌ទាំង៣នេះអាចបង្កើតទៅជាពណ៌ផ្សេងបានទាំងអស់<br>4. សួរក្មេងៗថាតើពួកគេគិតបែបណា នៅពេលដែល អ្នកលាយចូលគ្នានៃពណ៌ក្រហមជាមួយលឿង ខៀវនិងលឿង និងខៀវនិងក្រហម?<br>5. ពន្យល់ថាពណ៌ទឹកក្រូច បៃតង និងពណ៌ស្វាយ គឺជាពណ៌មេបន្ទាប់ពណ៌ទាំង៣ខាងលើ។<br>6. ចែកក្រដាសធម្មតា និងបង្ហាញក្មេងៗពីរបៀបបត់ក្រដាសជាពីរចំពាក់កណ្ដាល។<br>7. បង្ហាញពួកគេរបៀបធ្វើសកម្មភាពមួយនេះ។<br>8. ចែកទឹកពណ៌ឱ្យទៅកាន់ក្មេងៗ<br>9. ជួយក្មេងៗប្រសិនអាចទៅរួច។<br>10. ចែកក្រដាសធម្មតាឱ្យទៅក្មេងៗមួយទៀត ដូច្នេះពួកគេអាចលាយពណ៌ផ្សេងៗទៀត។<br>11. ខណៈពេលដែលពួកគេកំពុងរងចាំឱ្យក្រដាសរបស់ពួកគេស្ងួតនោះ ចូរនិយាយអំពីពណ៌ដែលពួកគេបានបង្កើត។ និងនិយាយម្តងទៀតថាពណ៌ក្រហម ពណ៌លឿង និងពណ៌ខៀវគឺជាពណ៌ដើម ពីព្រោះថាគ្មានពណ៌ណាដែលអាចបង្កើតបានជាពណ៌ទាំងបីនេះទេ។ | 2. លាតក្រដាស និងពង្រាយទឹកពណ៌ដែលមានផ្សេងៗពីគ្នាដូចជាដំណក់ទឹកភ្លៀង នៅផ្នែកទាំង២នៃក្រដាសនោះ (វាគួតែពង្រាយទឹកពណ៌គ្រប់គ្រាន់ដើម្បីបង្កើតជា)... តែកុំពង្រាយទឹកពណ៌ច្រើនពេក កុំឱ្យពេលយើងបត់ក្រដាសម្តងទៀត វាហូរទឹកពណ៌ចេញមកក្រៅ។<br>3. បត់ក្រដាសជាពាក់កណ្ដាលម្តងទៀត និងសង្កត់វា ពីលើក្រដាសដែលបត់នោះ ដើម្បីឱ្យទឹកពណ៌ជាប់ពេញក្រដាស<br>4. បើកក្រដាសម្តងទៀត ដើម្បីបានឃើញគំរូ និងពណ៌ដែលអ្នកបានបង្កើតនោះ។<br>5. ទុកឱ្យវាស្ងួតសិន<br>6. បត់វាម្តងទៀត និងកាត់ក្រដាសជារាងសត្វមេអំបៅ។ | 3. យកចិត្តទុកដាក់នៅពេលដែលគ្រូរបស់អ្នកពន្យល់ពីអ្វីដែលគាត់កំពុងធ្វើ។<br>4. ពង្រាយទឹកពណ៌ឱ្យពេញក្រដាសទាំងសងខាង។<br>5. បត់ក្រដាសជាពាក់កណ្ដាលម្តងទៀត និងសង្កត់វា ពីលើក្រដាសដែលបត់នោះ ដើម្បីឱ្យទឹកពណ៌ជាប់ពេញក្រដាស។<br>6. បើកក្រដាសម្តងទៀត ដើម្បីបានឃើញគំរូ និងពណ៌ដែលអ្នកបានបង្កើតនោះ។<br>7. នៅពេលដែលទឹកពណ៌បានស្ងួតហើយនោះ ក្មេងៗអាចកាត់ ឬហែកវាជារាងមេអំបៅជាការស្រេច។<br> |

| | | |
| --- | --- | --- |
| 12. ហើយពណ៌បៃតង ពណ៌ទឹកក្រូច និងពណ៌ស្វាយ គឺជាពណ៌បន្ទាប់ពីពណ៌ទាំង៣ខាងលើ ពីព្រោះពណ៌ទាំងនេះបានបង្កើតដោយលាយពណ៌ដើម២ពណ៌ចូលគ្នា។<br>13. នៅពេលដែលទឹកពណ៌បានស្ងួតហើយនោះ ក្មេងៗអាចកាត់ ឬហែកវាជារាងមេអំបៅជាការស្រេច។ | | |